**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តក្រចេះ**
លេខៈ០៣០/១៦ ដ.ក.ភ.ក

# ដីកា
# ស្តីពី
# ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ នៅរដ្ឋបាលខេត្តក្រចេះ

## អភិបាល នៃគណៈអភិបាលខេត្តក្រចេះ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៦/៤៦៦ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការតែងតាំងអភិបាល នៃគណៈអភិបាលខេត្តក្រចេះ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងសេចក្តីជូនដំណឹងលេខ ១៥២០ សជណ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ ស្តីពីការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ របស់ក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១ .–**

ត្រូវបានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ នៅរដ្ឋបាលខេត្តក្រចេះ ដែលមានសមាសភាព ដូចខាងក្រោមៈ

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **សរ ចំរុង** | អភិបាល នៃគណៈអភិបាលខេត្ត | ប្រធាន |
| ២- | លោក | **ជាក់ ម៉េងហ៊ាង** | អភិបាលរង នៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៣- | លោក | **ស្រេង សុភាព** | នាយករដ្ឋបាលសាលាខេត្ត | អនុប្រធាន |
| ៤- | លោក | **រស់ ដាវុធ** | ប្រធានមន្ទីរមុខងារសាធារណៈខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៥- | លោក | **អ៊ុច សុផាន់ណូ** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ៦- | លោក | **បេ គឹមឡាយ** | ប្រធានរតនាគារខេត្ត | សមាជិក |
| ៧- | លោក | **យិន វណ្ណា:** | អភិបាលក្រុងក្រចេះ | សមាជិក |
| ៨- | លោក | **គង់ គឹមនី** | អភិបាលស្រុកស្នួល | សមាជិក |

| | | | | |
|---|---|---|---|---|
| ៩- | លោក | **ហង់ ចាន់ឌី** | អភិបាលស្រុកចិត្របុរី | សមាជិក |
| ១០- | លោក | **ហេង សុថា** | អភិបាលស្រុកឆ្លូង | សមាជិក |
| ១១- | លោក | **សូម សារិត** | អភិបាលស្រុកសំបូរ | សមាជិក |
| ១២- | លោក | **សេក ម៉ិនហេង** | អភិបាលស្រុកព្រែកប្រសព្វ | សមាជិក |
| ១៣- | លោក | **ភ្រឹម ម៉ារ៉ាឌី** | អនុប្រធានមន្ទីរមុខងារសាធារណៈ | ជាមន្ត្រីបង្គោល |
| ១៤- | លោក | **ចាន់ រ៉េត** | ប្រធានការិយាល័យ នៃមន្ទីរមុខងារសាធារណៈ | ជាមន្ត្រីបង្គោល |

**ប្រការ ២ .-**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ នៅរដ្ឋបាលខេត្តក្រចេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខប្រធានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រង និងដឹកនាំ គ្រប់ការងារពាក់ព័ន្ធទៅនឹងកម្មវិធីយុទ្ធសាស្ត្រ និងសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈ របស់រដ្ឋបាលខេត្ត
- សម្របសម្រួល ការងារកែទម្រង់រដ្ឋបាលសាធារណៈ រវាងរដ្ឋបាលខេត្ត ជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- សម្របសម្រួល និងជម្រុញការងារអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពការងារកែទម្រង់រដ្ឋបាលសាធារណៈ
- ត្រៀមរៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងធ្វើរបាយការណ៍ ស្តីពីវឌ្ឍនភាព នៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ជូនប្រធានស្ថាប័នសាមីជាប្រចាំ
- ត្រូវរាយការណ៍អំពីវឌ្ឍនភាពឲ្យបានទៀងទាត់រៀងរាល់ត្រីមាស មកលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ រដ្ឋបាលសាធារណៈ
- ក្រុមការងារត្រូវផ្តល់កិច្ចសហការ និងសម្របសម្រួល ជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធាណៈតាមរយៈមន្ត្រីបង្គោល ក្នុងការស្វែងរកនិងប្រមូលព័ត៌មាន ការរៀបចំផែនការសកម្មភាពការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការរៀបចំរបាយការណ៍ និងបញ្ជូនរបាយការណ៍សង្ខេបនូវសេចក្តីត្រូវការ ដែលទាក់ទងទៅនឹងវឌ្ឍនភាព នៃការអនុវត្តកម្មវិធីជាតិកំណែ ទម្រង់រដ្ឋបាលសាធារណៈ របស់រដ្ឋបាលខេត្ត មកលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់ រដ្ឋបាលសាធារណៈ ឬនាយកដ្ឋានជំនាញនៃក្រសួងមុខងារសាធារណៈ។ ជាពិសេសមន្ត្រីបង្គោល ត្រូវបានចូលរួម វគ្គបណ្តុះបណ្តាល ស្តីពីប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់ការអនុវត្ត កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។

**ប្រការ ៣ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយទៅនឹងដីកានេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤ .-**

នាយករដ្ឋបាលសាលាខេត្ត អភិបាល នៃគណៈអភិបាលក្រុង ស្រុក នាយកទីចាត់ការ និងប្រធានអង្គភាពចំណុះរដ្ឋបាលខេត្ត ប្រធានមន្ទីរ និងអង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តដីកានេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ក្រចេះ ថ្ងៃទី ខែ សីហា ឆ្នាំ២០១៦

**អភិបាលខេត្ត**

**សរ ចំរុង**

**កន្លែងទទួល**
- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ ✓
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "ដើម្បីជូនជ្រាប"
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ